១

# មតរោទនជាតក



*ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈអ្នករស់នៅក្នុងក្រុងសាវត្ថីម្នាក់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **មតំ មតំ ឯវ រោទថ** *ដូច្នេះជាដើម ។*

*បានឮមកថា បងប្រុសរបស់កុដុម្ពិកៈនោះធ្វើមរណកាល ។ ដោយសារការស្លាប់របស់បងប្រុស កុដុម្ពិកៈនោះត្រូវសេចក្តីសោកស្តាយគ្របសង្កត់ មិនងូត មិនបរិភោគ មិនលាប, ពេលព្រឹក គាត់តែងទៅព្រៃស្មសាន យំសោកស្តាយបងប្រុស ។ ក្នុងបច្ចូសសម័យ ព្រះសាស្តាប្រមើលមើលសត្វលោក ឃើញឧបនិស្ស័យសោតាបត្តិផល របស់កុដុម្ពិកៈនោះ ទ្រង់ត្រិះរិះថា បើវៀរចាកតថាគតហើយ បុគ្គលដទៃណាមួយ ដែលមានសមត្ថភាព*

*អាចលើកហេតុការណ៍អតីត មកសម្តែងដល់កុដុម្ពិកៈនេះ ឲ្យគេរំងាប់សេចក្តីសោក ហើយប្រទានសោតាបត្តិផលដល់គេ រមែងមិនមាន, តថាគតគួរជាទីពឹងរបស់កុដុម្ពិកៈនេះ ។*

*ក្នុងថ្ងៃស្អែក ព្រះអង្គត្រឡប់ពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ទ្រង់យក* ***បច្ឆាសមណៈ****ទៅកាន់ទ្វារផ្ទះកុដុម្ពិកៈនោះ ។ កុដុម្ពិកៈឮដំណឹងថា ព្រះសាស្តាយាងមកដូច្នេះ គាត់ក៏ក្រាលអាសនៈ និមន្តព្រះសាស្តាថា សូមព្រះអង្គយាងចូល ។ ព្រះសាស្តាយាងចូលហើយ ទ្រង់ប្រថាប់លើអាសនៈ ដែលគាត់ក្រាលថ្វាយ ។ ចំណែកកុដុម្ពិកៈមកថ្វាយបង្គំ ព្រះសាស្តា ហើយគាត់អង្គុយក្នុងទីដ៏សមគួរ ។*

***គ្រានោះ ព្រះសាស្តាត្រាស់សួរគាត់ថា*** *ម្នាលកុដុម្ពិកៈ អ្នកគិតអ្វី ?*

***កុដុម្ពិកៈទូលថា*** *ព្រះករុណាព្រះអង្គ ចាប់តាំងពីបងប្រុសរបស់ខ្ញុំព្រះអង្គស្លាប់ ទៅខ្ញុំព្រះអង្គគិតពីគាត់ ។*

***ព្រះពុទ្ធត្រាស់ថា*** *ម្នាលអាវុសោ សង្ខារទាំងឡាយទាំងពួង មិនទៀងទេ, របស់ដែលត្រូវបែក រមែងបែកធ្លាយ, មិនគប្បីគិតក្នុងរបស់ត្រូវបែកធ្លាយនោះឡើយ ។ សូម្បីបោរាណកបណ្ឌិតទាំងឡាយ កាលបងប្រុសស្លាប់ ក៏មិនបានគិតច្រើន ដោយយល់ឃើញថា របស់ត្រូវបែកធ្លាយ រមែងបែកធ្លាយ ដូច្នេះហើយ កាលកុដុម្ពិកៈនោះអារាធនា ព្រះអង្គក៏នាំអតីតនិទានមកថា ៖*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តបានសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី ដែលមានទ្រព្យសម្បត្តិ ៨០ កោដិ ។ កាលលោកចម្រើនវ័យឡើង មាតាបិតារបស់លោក បានធ្វើមរណកាល ។ កាលមាតាបិតាស្លាប់ទៅ បងប្រុសរបស់ព្រះពោធិសត្វ បានបែងចែកទ្រព្យ, ព្រះពោធិសត្វរស់នៅដោយអាស្រ័យ*

*ទ្រព្យនោះ ។ កាលខាងក្រោយមក បងប្រុសនោះក៏បានធ្វើមរណកាល ដោយជំងឺបែបនោះដែរ ។ ពួកញាតិមិត្រដែលមានចិត្តល្អ មកជួបជុំគ្នា ផ្គងដើមដៃ កន្ទក់កន្ទេញ យំសោក ពុំមានអ្នកណាម្នាក់អាចតាំងនៅ ដោយសភាពខ្លួនឡើយ ចំណែកព្រះពោធិសត្វមិនកន្ទក់កន្ទេញ មិនយំសោកសោះ ។*

*មនុស្សទាំងឡាយតិះដៀលព្រះពោធិសត្វថា អ្នកទាំងឡាយចូរមើលចុះ បងប្រុសស្លាប់ម៉្យាងហើយ គាត់នេះមិនមានទឹកមុខក្រៀមក្រំបន្តិចសោះ ចិត្តដាច់ម៉្លេះ ប្រហែលជាគាត់ចង់ឲ្យបងស្លាប់ ដោយគិតថា អញនឹងបានប្រើប្រាស់ទ្រព្យទាំងពីរចំណែក តែម្នាក់ឯង ។ សូម្បីពួកញាតិវិញ ក៏តិះដៀលព្រះពោធិសត្វដូចគ្នាថា កាលបើបងស្លាប់ម៉្យាងហើយ អ្នកឯងមិនយំសោះ ។*

*ព្រះពោធិសត្វស្តាប់ពាក្យ របស់មនុស្សទាំងនោះហើយ លោកពោលថា អ្នកទាំងឡាយមិនដឹង**លោកធម៌**ទាំង ៨ ព្រោះភាពល្ងង់ខ្លៅងងឹតងងុលរបស់ខ្លួន, អ្នកទាំងឡាយយំដោយគិតថា បងប្រុសរបស់ខ្ញុំស្លាប់, សូម្បីខ្ញុំក៏នឹងស្លាប់, សូម្បីអ្នកទាំងឡាយក៏នឹងស្លាប់, ហេតុអ្វី ក៏អ្នកទាំងឡាយមិនយំសោកស្តាយខ្លួនថា យើងនឹងស្លាប់ផងទៅ ។ សង្ខារទាំងឡាយមិនទៀងទេ តែងរលត់ទៅ, សង្ខារសូម្បីមួយដែល អាចតាំងនៅតាមសភាវៈខ្លួនឡើយ រមែងមិនមានឡើយ, អ្នកទាំងឡាយជាមនុស្សល្ងង់ខ្លៅ មិនដឹងលោកធម៌ទាំង ៨ ព្រោះសេចក្តីវង្វេង ទើបយំ តើខ្ញុំនឹងយំដើម្បីអ្វី? លុះពោលដូច្នេះហើយ ព្រះពោធិសត្វក៏ពោលគាថាទាំងនេះថា*

**មតំ មតំ ឯវ រោទថ, ន ហិ តំ រោទថ យោ មរិស្សតិ,**
**សព្ពេបិ សរីរធារិនោ, អនុបុព្ពេន ជហន្តិ ជីវិតំ។**

*អ្នកទាំងឡាយ យំរកបុគ្គលស្លាប់ទៅហើយ ៗ តែម្យ៉ាង បុគ្គលណា បម្រុងស្លាប់ អ្នកទាំងឡាយ មិនយំរកបុគ្គលនោះសោះ ពួកសត្វទាំងអស់ ជាអ្នកទ្រទ្រង់នូវសរីរៈ តែងបង់នូវជីវិតតាមលំដាប់ ។*

ទេវមនុស្សា ចតុប្បទា, បក្ខិគណា ឧរគា ច ភោគិនោ;
សម្ហិ សរីរេ អនិស្សរា, រមមានាវ ជហន្តិ ជីវិតំ។

*ពួកទេវតា មនុស្ស សត្វជើង ៤ ពួកសត្វស្លាប និងពួកពស់ ប្រកបដោយភ្នែន មិនជាធំក្នុងសរីរៈឡើយ តែងលះបង់ជីវិត ទាំងកំពុងត្រេកអរ (ក្នុងឋានដែលខ្លួនកើតហើយ) ។*

ឯវំ ចលិតំ អសណ្ឋិតំ, សុខទុក្ខំ មនុជេស្វបេក្ខិយ;
កន្ទិតរុទិតំ និរត្ថកំ, កឹ វោ សោកគណាភិកីររេ។

*សុខនិងទុក្ខជាធម្មជាតកម្រើក មិនតាំងនៅយ៉ាងនេះ បុគ្គលគួរមិលមើល ក្នុងពួកមនុស្ស ការកន្ទក់កន្ទេញ ការយំសោកជារបស់មិនមានប្រយោជន៍ទេ ព្រោះហេតុអ្វី ក៏គំនរនៃសេចក្តីសោក គ្របសង្កត់អ្នកទាំងឡាយ ។*

ធុត្តា ច សោណ្ឌា អកតា, ពាលា សូរា អយោគិនោ;
ធីរំ មញ្ញន្តិ ពាលោតិ, យេ ធម្មស្ស អកោវិទា។

*ពួកជនណា ជាអ្នកលេង ជាអ្នកស្រវឹង មិនធ្វើ (សេចក្តីចម្រើន) ជាមនុស្សពាល ក្លៀវក្លា មិនមានសេចក្តីព្យាយាម មិនឈ្លាសក្នុងធម៌ ពួកជននោះ តែងសំគាល់នូវអ្នកប្រាជ្ញ (ដែលមិនយំសោកជាដើម) ថាជាមនុស្សពាលទៅវិញ ។*

*ព្រះពោធិសត្វសម្តែងធម៌ ដល់មនុស្សទាំងនោះ យ៉ាងនេះហើយ មនុស្សទាំងនោះសូម្បីទាំងអស់ ក៏ធ្វើសេចក្តីមិនសោក ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតក កាលចប់សច្ចៈ កុដុម្ពិកៈបានតាំងនៅក្នុងសោតាបត្តិផល ។*

**តទា មហាជនស្ស ធម្មំ ទេសេត្វា និស្សោកការកោបណ្ឌិតោ បន អហមេវ អហោសឹ** *បណ្ឌិតដែលធ្វើសេចក្តីមិនសោក សម្តែងធម៌ដល់មហាជន ក្នុងកាលនោះ គឺតថាគតនេះឯង ។*

*មតរោទនជាតក ចប់ ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត បុចិមន្ទវគ្គ បិដកលេខ ៥៨ ទំព័រ ២០៣)*

*ថ្ងៃពុធ ៧ រោច ខែអស្សុជ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ៣១ ខែ តុលា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*